ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៦. អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មាធិការពានរង្វាន់យុវជនដែលមានភាពជាអ្នកដឹកនាំប្រចាំឆ្នាំ

◊◊◊◊✦◊◊◊◊

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរចាំបាច់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការពានរង្វាន់យុវជនដែលមានភាពជាអ្នកដឹកនាំប្រចាំឆ្នាំ សរសេរកាត់ថា **គ.ព.យ.**។

www.pheakdeylaw.com

**មាត្រា ២.-**

គណៈកម្មាធិការពានរង្វាន់យុវជនដែលមានភាពជាអ្នកដឹកនាំប្រចាំឆ្នាំ ដឹកនាំដោយប្រធានមួយរូប ។

**មាត្រា ៣.-**

គណៈកម្មាធិការពានរង្វាន់យុវជនដែលមានភាពជាអ្នកដឹកនាំប្រចាំឆ្នាំ ស្ថិតនៅក្រោមការណែនាំ និងចង្អុលទិសរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ហើយមានភារកិច្ចដូចតទៅ :

- រៀបចំបង្កើត និងអនុវត្តនូវរាល់នីតិវិធីក្នុងការបង្កើតពានរង្វាន់យុវជនដែលមានភាពជាអ្នកដឹកនាំប្រចាំឆ្នាំ
- រៀបចំលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសបេក្ខជន សម្រាប់ទទួលពានរង្វាន់
- រៀបចំបញ្ជីឈ្មោះបេក្ខជន ដែលមានលក្ខណៈសម្បត្តិស្របតាមលក្ខណៈវិនិច្ឆ័យខាងលើជារៀងរាល់ឆ្នាំ
- ជ្រើសរើសបេក្ខភាពយ៉ាងតិចបីរូប ដើម្បីលើកសំណើជូនគណៈរដ្ឋមន្ត្រីធ្វើការសម្រេចផ្តល់ជ័យលាភី
- រៀបចំរបាយការណ៍បូកសរុបសកម្មភាពប្រចាំឆ្នាំ របស់គណៈកម្មាធិការពានរង្វាន់យុវជន ដែលមានភាពជាអ្នកដឹកនាំប្រចាំឆ្នាំ ។

**មាត្រា ៤.-**

គណៈកម្មាធិការពានរង្វាន់យុវជនដែលមានភាពជាអ្នកដឹកនាំប្រចាំឆ្នាំ មានសមាសភាព គឺ ០៣ រូប ពី រាជរដ្ឋាភិបាល ០២ រូប ពីផ្នែកឯកជន ០២ រូប ពីផ្នែកសង្គមស៊ីវិល ០២ រូប ពីផ្នែកសង្គមកម្ពុជា និង ០២ រូប ពីអង្គការយុវជន ។ ប្រធានមានសិទ្ធិស្នើសុំតែងតាំងអនុប្រធាន និងសមាជិក ។ សមាសភាពជាក់ស្តែងត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៥.-**

គណៈកម្មាធិការពានរង្វាន់យុវជនដែលមានភាពជាអ្នកដឹកនាំប្រចាំឆ្នាំ មានអគ្គលេខាធិការដ្ឋានមួយ ជាសេនាធិការដែលដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយរូប ជាជំនួយការ ។

**មាត្រា ៦.-**

គណៈកម្មាធិការពានរង្វាន់យុវជនដែលមានភាពជាអ្នកដឹកនាំប្រចាំឆ្នាំ ធ្វើការប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន អនុប្រធាន ឬតាមការណែនាំរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

www.pheakdeylaw.com

មាត្រា ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com